# លិខិតជូនពររបស់លោក កឹម សុខា
# ប្រធានគណបក្សសិទ្ធិមនុស្ស
# ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ
# ឆ្នាំខាល ទោស័ក ពុទ្ធសករាជ ២៥៥៤

**សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ !**

**សូមគោរព សមាជិក សមាជិកា គណបក្សសិទ្ធិមនុស្ស និងបងប្អូនប្រជាពលរដ្ឋ**

**ជាទីគោរពស្រលាញ់រាប់អាន !**

ឆ្នាំចាស់ ឆ្នាំឆ្លូវបានកន្លងផុតទៅ ដោយបន្សល់ទុកនូវបញ្ហាជាច្រើន ជុំវិញការអនុវត្តលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្សនៅព្រះរាជាណាចក្រកម្ពុជាយើង។ ក្រោយពីជាងដប់ឆ្នាំនៃរបបប្រជាធិបតេយ្យ សេរីពហុបក្ស ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ យើងសង្កេតឃើញនូវមានការបាញ់ប្រហារប្រជាពលរដ្ឋក្រីក្រក្នុងទំនាស់ដណ្តើមដីធ្លី ការប្តឹងផ្តល់រវាងអ្នកនយោបាយ រហូតដល់ការដកអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រ ការចាប់អ្នកសារពតិមានដាក់ពន្ធនាគារ ។ល។ បញ្ហាសង្គមជាច្រើនទៀតរួមមានការសេព ជួញដូរគ្រឿងញៀន ការលក់ជួញដូរផ្លូវភេទស្ត្រីកុមារ សីលធម៌សង្គមធ្លាក់ចុះ អសន្តិសុខ អំពើពាលា អាវ៉ាសែ ។ល។

ជាមួយគ្នានឹងការឆ្លងហួសទៅនៃឆ្នាំចាស់ ប្រជាពលរដ្ឋខ្មែរគ្រប់រូប ដែលមានភ័ព្វវាសនាបន្តជីវភាពរស់នៅក្នុងឆ្នាំថ្មី គួរតែមានមោទនភាពយ៉ាងក្រៃលែង ធ្វើខ្លួនយ៉ាងសក្តិសមក្នុងនាមជា ប្រជាជាតិមួយធ្លាប់មានវប្បធម៌ អរិយធម៌ថ្លៃថ្នូរ សីលធម៌ខ្ពស់ គោរពសិទ្ធិមនុស្ស ដើរតាមគន្លងលទ្ធិប្រជាធិបតេយ្យពិតប្រាកដ។ **គណបក្សសិទ្ធិមនុស្ស** ក្នុងទស្សនវិស័យ " **ចង់ឃើញប្រទេសកម្ពុជាមួយ ដែលប្រជាពលរដ្ឋមានឱកាសស្មើគ្នា ដើម្បីស្វែងរកជីវភាពរស់នៅឱ្យបានល្អប្រសើរ** " បានប្រកាន់ខ្ជាប់នូវជំហរច្បាស់លាស់ និងដោយប្រាកដនិយមក្នុងការបំពេញភារកិច្ចជាប្រវត្តិសាស្ត្ររបស់ខ្លួនគឺ :

- លើកស្ទួយ និងពង្រឹងនូវលទ្ធិប្រជាធិបតេយ្យសេរី


Address: #72-74, Street 598, Sangkat Boeung Kok 2, Khan Tuol Kok, Phnom Penh, Cambodia.
Tel: (+855) 17 303 900 / 023 884 649 | Email: hrpcambodia@yahoo.com| Website: www.hrpcambodia.info

- ជម្រុញឱ្យមានការគោរពសិទ្ធិមនុស្ស
- ជម្រុញឱ្យអនុវត្ត នូវគោលការណ៍នីតិរដ្ឋ

ដូចជាការប្តេជ្ញាចិត្តរបស់ **គណបក្សសិទ្ធិមនុស្ស** ដោយមានការចូលរួម និងគាំទ្រយ៉ាងសកម្ម ពីសំណាក់ប្រជាពលរដ្ឋទូទាំងប្រទេស រួមទាំងអ្នកកំពុងរងទុក្ខវេទនា អ្នកកំពុងទទួលរងការឈឺចាប់ និងអ្នកដែលកំពុងចង់បានអនាគតភ្លឺស្វាងសំរាប់ក្រុមគ្រួសារ កូនចៅរបស់គេ។

ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ បងប្អូនប្រជាពលរដ្ឋខ្មែរ ដែលបានជួយគាំទ្រនូវសកម្មភាពរបស់គណបក្សសិទ្ធិមនុស្ស ក្នុងរយៈកាលកន្លងមកនេះ ដើម្បីបុព្វហេតុជំរុញឱ្យមានការអនុវត្តន៏លទ្ធិប្រជាធិបតេយ្យពិតប្រាកដនៅក្នុងប្រទេសយើង។ ខ្ញុំក៏សូមកោតសរសើរផងដែរ ចំពោះភាពអង់អាចក្លាហាន និងការលះបង់គ្រប់បែបយ៉ាង ដែលបងប្អូនប្រជាពលរដ្ឋ ពិសេសសមាជិក សមាជិកាគណបក្សសិទ្ធិមនុស្ស នៅក្នុងប្រទេស និងក្រៅប្រទេស ដែលបានធ្វើកន្លងមកនៅក្នុងឆ្នាំចាស់ ទោះបីមានការអុកឡុករំខាន បង្កឱ្យមានការភ័យខ្លាច មានការគាបសង្កត់ គំរាមកំហែង និងមានជីវភាពខ្វះខាតយ៉ាងណាក៏ដោយ ក៏បងប្អូនសមាជិក សមាជិកា បានចូលរួមយ៉ាងសស្រោកសស្រាំក្នុងបុព្វហេតុលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សនៅប្រទេសយើង។ ការរួមចំណែកនេះគឺពិតជាបានទទួលនូវផ្លែផ្កាប្រជាធិបតេយ្យ ជីវភាពរស់នៅសមរម្យដល់បងប្អូនប្រជាពលរដ្ឋទាំងអស់នៅពេលអនាគតជាមិនខាន។

ក្នុងឱកាសចូលឆ្នាំថ្មី ប្រពៃណីជាតិ " ឆ្នាំ ខាល ទោស័ក ពុទ្ធសករាជ ២៥៥៤ " ត្រូវនឹងថ្ងៃពុធ ទី១៤ ខែមេសា ឆ្នាំ ២០១០ ដ៏មហោឡារិកនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ **កឹម សុខា** ក្នុងនាមប្រធានគណបក្សសិទ្ធិមនុស្ស មានកិត្តិយស និងមានសេចក្តីសោមនស្ស សូមពិត ថេរៈដីកា គោរពជំរាប ជូនថា : ការមានជីវភាពរុងរឿង មានសុភមង្គល មានសុខដុម្បរមនា មានភាពស្ងប់ក្នុងសន្តិភាព គឺមានតែប្រជាពលរដ្ឋ ជាម្ចាស់អំណាចនេះហើយដែលជាអ្នកកំណត់ និងស្វែងរកដោយខ្លួនឯង តាមរយៈការសម្តែងមតិ ការទាមទារ ការតវ៉ាតាមផ្លូវច្បាប់។ រាល់ការសម្តែង ការបញ្ចេញនូវទស្សនៈ ការទាមទារ ការតវ៉ា គឺជាសិទ្ធិរបស់ប្រជាពលរដ្ឋ ដោយមានការការពារពីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ យើងក៏ដឹងដែរថា ការតស៊ូរបស់ប្រជាពលរដ្ឋ ដើម្បីបុព្វហេតុខាងលើនេះ តែងតែជួបឧបសគ្គជាច្រើន។ ឧបសគ្គទាំងនេះយើងអាចជំនះបាន លុះត្រាតែបងប្អូនប្រជាពលរដ្ឋមានអំណត់ព្យាយាមតស៊ូ លះបង់បន្តប្រកបដោយឆន្ទៈ និងមនសិការស្របតាមទស្សនៈ របស់គណបក្សសិទ្ធិមនុស្ស" **គ្មានកម្លាំងណា គ្មានអំណាចណា អាចយកឈ្នះលើឆន្ទៈរួមរបស់ប្រជាពលរដ្ឋបានឡើយ** "។

**គណបក្សសិទ្ធិមនុស្ស** យល់ឃើញថា មានតែការធ្វើបូនីយកិច្ចរួមគ្នារបស់ប្រជាពលរដ្ឋ ទាមទារសិទ្ធិសេរីភាព លទ្ធិប្រជាធិបតេយ្យពិតប្រាកដទេ ទើបជីវិតបានថ្លៃថ្នូរ និងរុងរឿង " **ប្រើប្រាស់សិទ្ធិដើម្បីជីវិតថ្លៃថ្នូ** " " **អនុវត្តប្រជាធិបតេយ្យ ដើម្បីជីវិតរុងរឿង** " **យើងតស៊ូដើម្បីសេរីភាព យុត្តិធម៌ និងការរីកចំរើន ដោយសន្តិវិធី ដោយគ្មានតក់ស្លុត** "។

ខ្ញុំព្រះករុណា ខ្ញុំបាទ សូមព្រះករុណាគ្រប់ព្រះអង្គ និងបងប្អូនប្រជាពលរដ្ឋ ជនរួមជាតិជាទីគោរព បានសំរាក និងជ្រះថ្លា ក្នុងអារម្មណ៍ ធ្វើបុណ្យសុន្ទរីទានតាមគន្លងប្រពៃណី ព្រះពុទ្ធសាសនា សូមឱ្យពុទ្ធឱវាទ របស់ព្រះសមណគោត្តមបរមគ្រូនៃយើង មានពិតក្នុងក្រអៅបេះដូង ពុទ្ធសាសនិកជនគ្រប់រូប ពោលគឺ " **មានព្រះក្នុងអារម្មណ៍ មានព្រះក្នុងបេះដូង** " បំបាត់អំពើហិង្សាគ្រប់ប្រភេទ អសីលធម៌ និងភាពទុរគតចេញពីសង្គមយើង។ សូមឱ្យការកំសាន្តសប្បាយ របស់បងប្អូនប្រជាពលរដ្ឋ ក្មួយៗជាយុវជន យុវនារីដោយល្បែងប្រជាប្រិយនានា ប្រកបដោយសភាពថ្លៃថ្នូរ និងការគោរពទំនៀមទំលាប់សីលធម៌ល្អ របស់យើង ប្រមូលផ្តុំគំនិត គិតត្រឹមត្រូវ ដោយភាពជ្រះថ្លា។

ឆ្លៀតឱកាសដ៏មហាប្រសើរនេះដែរ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមឧទ្ទិសឆ្នាំថ្មីតំរង់អារម្មណ៍ជនមួយចំនួន ដែលធ្លាប់ផ្តាច់ការ មានទម្លាប់គិត និងប្រព្រឹត្តខុសបែរមករកផ្លូវត្រូវ គឺការអនុវត្តន៍តាមគន្លងលទ្ធិប្រជាធិបតេយ្យសេរី ដើម្បីសង្គ្រោះជាតិ មាតុភូមិយើង។

ខ្ញុំព្រះករុណា ខ្ញុំបាទ សូមប្រសិទ្ធិពរជ័យ សិរីមង្គល វិបុលសុខ គ្រប់ប្រការ ចូរមានដល់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ សមាជិក សមាជិកាគណបក្សសិទ្ធិមនុស្ស និងបងប្អូនជនរួមជាតិទាំងអស់ជៀសផុតពីការរំលោភបំពាននានា មានការរំលោភសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយជាដើមពីសំណាក់ជនមានអំណាចមួយចំនួន ពិសេសទទួលបាននូវសេចក្តីសុខ សន្តិភាព សិទ្ធិសេរីភាព និងសុភមង្គល កុំបីឃ្លៀងឃ្លាតឡើយ។

**ពីទូលបង្គំ ខ្ញុំបាទ**

**គឹម សុខា**